ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៤៥៤២ កសក

រាជធានីភ្នំពេញ, ថ្ងៃទី ១០......ខែ..វិច្ឆិកា...ឆ្នាំ ២០១៦

**សូមគោរពជូន**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ ៖** របាយការណ៍ប្រចាំសប្ដាហ៍ស្ដីពី សភាពការណ៍ល្បឿនការងារប្រមូលផលដំណាំស្រូវវស្សាឆ្នាំ២០១៦ និងល្បឿនការងារបង្កបង្កើនផលដំណាំស្រូវប្រាំងឆ្នាំ២០១៦-២០១៧។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតជម្រាបជូន **សម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់មេត្តាជ្រាប អំពីសភាពការណ៍ល្បឿនការងារប្រមូលផលដំណាំស្រូវវស្សាឆ្នាំ២០១៦ និងល្បឿនការងារបង្កបង្កើនផលដំណាំស្រូវប្រាំងឆ្នាំ២០១៦-២០១៧ គិតត្រឹមថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ មានដូចតទៅ ÷

## I. លទ្ធផលបញ្ចប់ការងារបង្កបង្កើនផលស្រូវវស្សាឆ្នាំ២០១៦ ÷

### ១- ការងារដាំដុះ ÷

ក- ភ្ជួររាស់រៀបចំដីសម្រេចបានចំនួន ៣ ០០១ ០៨៥ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោក្របីចំនួន ២៦៥ ១០២ហ.ត (ស្មើនឹង ៨,៨៣%) និងដោយគ្រឿងយន្តកសិកម្មចំនួន ២ ៧៣៥ ៩៨៣ហ.ត (ស្មើនឹង ៩១,១៧%) តិចជាងឆ្នាំមុន៥៥២ ៨០២ហ.ត។

ខ- សាបសម្រេចបានចំនួន ៥០ ៦១៩ហ.ត តិចជាងឆ្នាំមុន ២០ ៤៥៤ហ.ត។

គ- ស្ទូងនិងព្រោះសម្រេចបានចំនួន ២ ៥៩៧ ៤១២ហ.ត ស្មើនឹង ១០៤,៨៨%នៃផែនការ ២ ៤៧៦ ៤៤៦ហ.ត លើសឆ្នាំមុន៤២ ២៩៤ហ.ត ស្មើនឹង ៥,៣៥% ÷

### ២- ល្បឿនការងារប្រមូលផលស្រូវវស្សាឆ្នាំ២០១៦ (ដូចមានតារាងជូនភ្ជាប់)÷

ការងារប្រមូលផលស្រូវវស្សា រហូតមកដល់ពេលនេះ សម្រេចបានចំនួន ៤០១ ២២៩ហ.ត លើផ្ទៃដីអនុវត្តសរុប ២ ៥៩៧ ៤១២ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ១ ៤៣៣ ២៨៦តោន លើសឆ្នាំមុន ៣៥០ ៩៧៧តោន។ ទិន្នផលគិតជាមធ្យម ៣,៥៧២តោន/ហ.ត (សប្ដាហ៍មុន ៣,៧១៦តោន/ហ.ត) លើសឆ្នាំមុន ៣៦៣គ.ក្រ/ហ.ត។

## II. ល្បឿនការងារបង្កបង្កើនផលស្រូវប្រាំងឆ្នាំ២០១៦-២០១៧ (ដូចមានតារាងជូនភ្ជាប់)÷

- លទ្ធផលភ្ជួររាស់រៀបចំដីសម្រេចបានចំនួន ៨៤ ៣១២ហ.ត តិចជាងឆ្នាំមុនចំនួន ៧២ ០៦៩ហ.ត ក្នុងនោះ ភ្ជួររាស់ដោយគោ ក្របីចំនួន ៥ ៩៩១ហ.តស្មើនឹង ៧,១១% និងដោយគ្រឿងយន្តចំនួន ៧៨ ៣២១ហ.តស្មើនឹង ៩២,៨៩%
- សាបបានសរុបចំនួន ៥២២ហ.ត លើសឆ្នាំមុនចំនួន ១៦៤ហ.ត
- ស្ទូងនិងព្រោះសម្រេចបានចំនួន ៤៣ ៩៨១ហ.ត ស្មើនឹង ១០,២៤%នៃផែនការ ៤២៩ ៣៥៥ហ.ត តិចជាងឆ្នាំមុន ៤៩ ៥៨៥ហ.ត។

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨/៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
No. 200 , Preah Norodom Sangkat Tonle Basak Khan Chamkamon B V D, Phnom Penh, Cambodia Phone : (023) 726 128 / 726 129, Fax : (855) 23 217-320

**III. ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៦-២០១៧** (ដូចមានតារាងជូនភ្ជាប់)÷

ក- ផ្ទៃដីដំណាំរួមផ្សំ អនុវត្តបានចំនួន ៤ ២៤៣ហ.ត ស្មើនឹង ៥,៧៩% នៃផែនការ ៧៣ ២៤៩ហ.ត លើសឆ្នាំមុន ១ ៦៥៤ ហ.ត។

ខ -ផ្ទៃដីដំណាំឧស្សាហកម្ម អនុវត្តបានចំនួន ៣៩៤ហ.ត ស្មើនឹង ២,៧៩% នៃផែនការ ១៤ ១២១ហ.ត តិចជាងឆ្នាំមុន ១០០ហ.ត។

**IV. សេចក្តីសន្និដ្ឋាន**

ជារួមការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៦ បានបញ្ចប់ជាស្ថាពរហើយ ដោយសម្រេចបាន ២ ៥៩៧ ៤១២ហត ស្មើនឹង **១០៤,៨៥%** នៃផែនការ ២ ៤៧៦ ៤៤៦ហត លើសឆ្នាំមុនចំនួន ៤៥ ៨៩៨ហត។ មកទល់ពេលនេះ ប្រជាកសិករបាននិងកំពុងជំរុញការងារប្រមូលផលដំណាំរដូវវស្សាយ៉ាងសកម្ម ក្នុងនោះ ល្បឿននៃការប្រមូលផលស្រូវរដូវវស្សាគឺស្មើនឹង ១៥,៤៥% នៃផ្ទៃដីអនុវត្ត ២ ៥៩៧ ៤១២ហត ដែលទទួលបានទិន្នផលគិតជាមធ្យម **៣,៥៧២តោន/ហ.ត** និងខិតខំជំរុញការដាំដុះដំណាំរដូវប្រាំងជាបន្តទៅទៀត។ ទន្ទឹមនឹងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងបន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការខិតខំថែទាំដំណាំស្រូវ យកចិត្តទុកដាក់លើការគ្រប់គ្រងនិងរក្សាទឹកទុកឱ្យបានគត់មត់សម្រាប់រដូវប្រាំង ក៏ដូចជាការថែទាំដំណាំផ្សេងៗ ព្រមទាំងជំរុញការធ្វើកសិកម្មចម្រុះឱ្យអស់ពីលទ្ធភាពនៅកន្លែងដែលមានប្រភពទឹកគ្រប់គ្រាន់។ ដោយឡែក ក្រសួងបន្តចុះពិនិត្យតាមដានការចាក់វ៉ាក់សាំងការពារជំងឺឆ្លងសត្វផ្សេងៗ និងចាត់ក្រុមអន្តរាគមន៍ចុះទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្តជាប់ជាប្រចាំ។

សេចក្តីដូចបានគោរពរាយការណ៍ជូនខាងលើនេះ ខ្ញុំបាទសូម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់ មេត្តាជ្រាបដោយក្តីអនុគ្រោះ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅបំផុតអំពីខ្ញុំបាទ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ចម្លងជូន ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

  **"ដើម្បីជូនជ្រាប"**
- ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

  **"ដើម្បីជ្រាប"**
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផែនការ និង ស្ថិតិ

# ល្បឿនការងារប្រមូលផលស្រូវរដូវវស្សាឆ្នាំ ២០១៦

(គិតត្រឹមថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ផ្ទៃដីអនុវត្ត (ហត) | | ផ្ទៃដីប្រមូលផល | ទិន្នផល | បរិមាណផល | ភាគរយ | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|---|
| | | សរុប | ស្រូវស្រាល | (ហត) | (តោន/ហ.ត) | (តោន) | (%) | |
| 01 | បន្ទាយមានជ័យ | 247,015 | 53,235 | 39,177 | 4.583 | 179,567 | 15.86 | 17-10-2016 |
| 02 | បាត់ដំបង | 289,567 | 73,924 | 81,401 | 3.989 | 324,738 | 28.11 | 08-11-2016 |
| 03 | កំពង់ចាម | 89,861 | 26,096 | 14,702 | 3.580 | 52,628 | 16.36 | 08-11-2016 |
| 04 | កំពង់ឆ្នាំង | 124,409 | 7,668 | 2,199 | 3.040 | 6,684 | 1.77 | 07-11-2016 |
| 05 | កំពង់ស្ពឺ | 115,116 | 13,231 | 653 | 3.352 | 2,189 | 0.57 | 07-09-2016 |
| 06 | កំពង់ធំ | 215,526 | 31,300 | 23,392 | 2.376 | 55,571 | 10.85 | 08-11-2016 |
| 07 | កំពត | 138,388 | 22,651 | 22,651 | 3.712 | 84,078 | 16.37 | 10-10-2016 |
| 08 | កណ្តាល | 35,329 | 10,831 | 9,181 | 3.762 | 34,542 | 25.99 | 26-10-2016 |
| 09 | កោះកុង | 10,503 | 2,237 | 448 | 2.487 | 1,114 | 4.27 | 08-11-2016 |
| 10 | ក្រចេះ | 33,072 | 13,091 | 13,109 | 3.170 | 41,556 | 39.64 | 02-11-2016 |
| 11 | មណ្ឌលគិរី | 23,608 | 3,392 | 1,595 | 2.861 | 4,564 | 6.76 | 10-11-2016 |
| 12 | ភ្នំពេញ | 10,291 | 4,232 | 147 | 3.020 | 444 | 1.43 | 27-09-2016 |
| 13 | ព្រះវិហារ | 82,398 | 13,499 | | | | - | |
| 14 | ព្រៃវែង | 270,111 | 64,832 | 50,158 | 3.617 | 181,408 | 18.57 | 07-11-2016 |
| 15 | ពោធិ៍សាត់ | 115,984 | 49,186 | 24,758 | 3.123 | 77,319 | 21.35 | 07-11-2016 |
| 16 | រតនគិរី | 24,011 | 2,967 | | | | - | |
| 17 | សៀមរាប | 186,735 | 39,700 | 25,215 | 2.423 | 61,098 | 13.50 | 08-11-2016 |
| 18 | ព្រះសីហនុ | 16,605 | 1,500 | 1,500 | 1.800 | 2,700 | 9.03 | 04-11-2016 |
| 19 | ស្ទឹងត្រែង | 28,678 | 10,697 | 7,563 | 2.500 | 18,907 | 26.37 | 02-11-2016 |
| 20 | ស្វាយរៀង | 168,528 | 59,117 | 18,547 | 3.100 | 57,496 | 11.01 | 08-11-2016 |
| 21 | តាកែវ | 197,444 | 93,333 | 54,801 | 4.045 | 221,691 | 27.76 | 08-11-2016 |
| 22 | ឧត្តរមានជ័យ | 86,501 | 20,119 | 5,615 | 1.934 | 10,858 | 6.49 | 08-11-2016 |
| 23 | កែប | 3,597 | 1,109 | 517 | 3.549 | 1,835 | 14.37 | 27-09-2016 |
| 24 | ប៉ៃលិន | 5,825 | 1,660 | 133 | 2.504 | 333 | 2.28 | 10-11-2016 |
| 25 | ត្បូងឃ្មុំ | 78,310 | 12,901 | 3,767 | 3.177 | 11,966 | 4.81 | 04-11-2016 |
| | សរុប | **2,597,412** | **632,508** | **401,229** | **3.572** | **1,433,286** | **15.45** | |
| | តួលេខសប្តាហ៍មុន | **2,597,412** | **632,508** | **350,974** | **3.716** | **1,304,072** | **13.51** | |
| | តួលេខឆ្នាំ២០១៥ | **2,555,118** | **584,804** | **337,267** | **3.209** | **1,082,309** | **13.20** | |
| | ប្រៀបធៀបឆ្នាំមុន | **42,294** | **47,704** | **63,962** | **0.363** | **350,977** | **2.25** | |

បានឃើញនិងឯកភាព
ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៦
ប្រធានការិយាល័យស្ថិតិ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
នាយកដ្ឋានផែនការ និង ស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ល្បឿនការងារបង្កបង្កើនផលស្រូវរដូវប្រាំងឆ្នាំ២០១៦-២០១៧

(គិតត្រឹមថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦ )

| ល.រ | រាជធានី-ខេត្ត | ផែនការ (ហ.ត) | ផ្ទៃដីភ្ជួររាស់ | | | | | ផ្ទៃដីសាប (ហ.ត) | ផ្ទៃដីស្ទូង និងព្រោះ (ហត) | | | ភាគរយ | ថ្ងៃខែរាយការណ៍ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | សរុប (ហ.ត) | គោ-ក្របី | | គ្រឿងយន្ត | | | សន្ទូង | ព្រោះ | សរុប | | |
| | | | | ហ.ត | % | ហ.ត | % | | | | | | |
| 01 | បន្ទាយមានជ័យ | 17,870 | 5,144 | - | - | 5,144 | 100.00 | 1 | 30 | 5,055 | 5,085 | 28.46 | 07-11-2016 |
| 02 | បាត់ដំបង | 12,000 | - | | - | | - | | | | - | - | |
| 03 | កំពង់ចាម | 42,000 | - | | - | | - | | | | - | - | |
| 04 | កំពង់ឆ្នាំង | 30,700 | 258 | - | - | 258 | 100.00 | - | - | 258 | 258 | 0.84 | 07-11-2016 |
| 05 | កំពង់ស្ពឺ | 550 | - | | - | | - | | | | - | - | |
| 06 | កំពង់ធំ | 36,000 | 1,253 | - | - | 1,253 | 100.00 | 5 | - | 1,098 | 1,098 | 3.05 | 08-11-2016 |
| 07 | កំពត | 7,000 | - | | - | | - | | | | - | - | |
| 08 | កណ្តាល | 55,800 | 2,021 | 758 | 38 | 1,263 | 62 | - | - | 948 | 948 | 1.70 | 10-11-2016 |
| 09 | កោះកុង | - | - | | - | | - | | | | - | - | |
| 10 | ក្រចេះ | 14,000 | 13,998 | 1,420 | 10.14 | 12,578 | 89.86 | 21 | 50 | 5,169 | 5,219 | 37.28 | 31-10-2016 |
| 11 | មណ្ឌលគិរី | | - | | - | | - | | | | - | - | |
| 12 | ភ្នំពេញ | 1,150 | 10,300 | 3,299 | 32 | 7,001 | 68 | 445 | 3,110 | 7,181 | 10,291 | 894.87 | 08-11-2016 |
| 13 | ព្រះវិហារ | 130 | - | | - | | - | | | | - | - | |
| 14 | ព្រៃវែង | 75,000 | 10,237 | - | - | 10,237 | 100.00 | - | - | 10,237 | 10,237 | 13.65 | 07-11-2016 |
| 15 | ពោធិ៍សាត់ | 9,000 | 1,670 | - | - | 1,670 | 100.00 | - | - | 782 | 782 | 8.69 | 07-11-2016 |
| 16 | រតនៈគិរី | | - | | - | | - | | | | - | - | |
| 17 | សៀមរាប | 20,925 | - | | - | | - | | | | - | - | |
| 18 | ព្រះសីហនុ | | - | | - | | - | | | | - | - | |
| 19 | ស្ទឹងត្រែង | 100 | - | | - | | - | | | | - | - | |
| 20 | ស្វាយរៀង | 20,000 | 1,298 | - | - | 1,298 | 100.00 | - | - | 1,298 | 1,298 | 6.49 | 01-11-2016 |
| 21 | តាកែវ | 75,000 | 35,643 | 364 | 1.02 | 35,279 | 98.98 | - | - | 6,560 | 6,560 | 8.75 | 08-11-2016 |
| 22 | ឧត្តរមានជ័យ | 600 | - | | - | | - | | | | - | - | |
| 23 | កែប | 30 | - | | - | | - | | | | - | - | |
| 24 | ប៉ៃលិន | 1,000 | - | | - | | - | | | | - | - | |
| 25 | ត្បូងឃ្មុំ | 10,500 | 2,490 | 150 | 6.02 | 2,340 | 93.98 | 50 | 45 | 2,160 | 2,205 | 21.00 | 04-11-2016 |
| | **សរុប** | **429,355** | **84,312** | **5,991** | **7.11** | **78,321** | **92.89** | **522** | **3,235** | **40,746** | **43,981** | **10.24** | |
| | **តួលេខឆ្នាំមុន** | **417,325** | **156,381** | **14,231** | **9.10** | **142,150** | **90.90** | **358** | **1,387** | **92,179** | **93,566** | **22.42** | |
| | **ប្រៀបធៀបឆ្នាំមុន** | **12,030** | **-72,069** | **-8,240** | **-1.99** | **-63,829** | **1.99** | **164** | **1,848** | **-51,433** | **-49,585** | | |

បានឃើញនិងឯកភាព
ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៦
ប្រធានការិយាល័យស្ថិតិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
នាយកដ្ឋានផែនការនិងស្ថិតិ

# ល្បឿនការងារបង្កបង្កើនផលដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៦-២០១៧

(គិតត្រឹមថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៦)

| ល.រ | រាជធានី-ខេត្ត | ពោត (ហ.ត) | | | | ដំឡូងឈើ (ហ.ត) | | ដំឡូងជ្វា (ហ.ត) | | បន្លែគ្រប់មុខ (ហ.ត) | | សណ្តែកបាយ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | | អនុវត្ត | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | % |
| | | សរុប | ក្រហម | សរុប | ក្រហម | | | | | | | | | | | |
| 01 | បន្ទាយមានជ័យ | 225 | - | | | 6,250 | | - | | 1,325 | | 120 | | 7,920 | - | - |
| 02 | បាត់ដំបង | 460 | | | | | | 50 | | 960 | | 300 | | 1,770 | - | - |
| 03 | កំពង់ចាម | 1,010 | 150 | | | 20 | | 760 | | 2,380 | | 150 | | 4,320 | - | - |
| 04 | កំពង់ឆ្នាំង | 1,090 | 170 | | | 90 | | 230 | | 1,860 | | 1,800 | | 5,070 | - | - |
| 05 | កំពង់ស្ពឺ | 4 | - | | | 0 | | 0 | | 190 | | 0 | | 194 | - | - |
| 06 | កំពង់ធំ | 130 | - | | | 90 | | 60 | | 345 | | 20 | | 645 | - | - |
| 07 | កំពត | 200 | - | | | 135 | | 245 | | 590 | | 255 | | 1,425 | - | - |
| 08 | កណ្តាល | 8,101 | 6,620 | | | 225 | | 190 | | 5,056 | | 4,307 | | 17,879 | - | - |
| 09 | កោះកុង | 27 | - | | | 3 | | 5 | | 60 | | - | | 95 | - | - |
| 10 | ក្រចេះ | 1,800 | 1,700 | 497 | 278 | - | | 80 | | 420 | 91 | 40 | - | 2,340 | 588 | 25.13 |
| 11 | មណ្ឌលគិរី | - | - | | | - | | - | | - | | - | | - | - | - |
| 12 | ភ្នំពេញ | 130 | - | | | - | | - | | 342 | | - | | 472 | - | - |
| 13 | ព្រះវិហារ | - | - | | | - | | - | | 782 | | - | | 782 | - | - |
| 14 | ព្រៃវែង | 1,825 | 1,825 | | | 200 | | 10 | | 790 | | 1,425 | | 4,250 | - | - |
| 15 | ពោធិ៍សាត់ | 200 | 100 | 33 | | 850 | 27 | 350 | | 500 | 54 | 300 | 2 | 2,200 | 116 | 5.27 |
| 16 | រតនគិរី | | | | | | | | | | | | | - | - | - |
| 17 | សៀមរាប | 830 | - | | | 2,490 | | 265 | | 2,040 | | 1,850 | | 7,475 | - | - |
| 18 | ព្រះសីហនុ | 35 | | | | 140 | | 20 | | 175 | | | | 370 | - | - |
| 19 | ស្ទឹងត្រែង | 250 | - | | | - | | - | | 450 | | 500 | | 1,200 | - | - |
| 20 | ស្វាយរៀង | | | | | 7,100 | | 110 | | 1,170 | | - | | 8,380 | - | - |
| 21 | តាកែវ | 232 | - | 109 | - | 398 | 1,698 | 110 | 397 | 648 | 842 | - | 169 | 1,388 | 3,215 | 231.63 |
| 22 | ឧត្តរមានជ័យ | 9 | - | | | 0 | | - | | 65 | | - | | 74 | - | - |
| 23 | កែប | 150 | 30 | | | 30 | | 100 | | 200 | | - | | 480 | - | - |
| 24 | ប៉ៃលិន | 2,005 | 2,000 | 298 | - | 1,500 | | | | 15 | | 1,000 | 26 | 4,520 | 324 | 7.17 |
| 25 | ត្បូងឃ្មុំ | 5,210 | 8,942 | | | - | | 400 | | 1,145 | | 490 | | 10,977 | - | 13,012 |
| **សរុប** | | **18,713** | **12,595** | **937** | **278** | **19,521** | **1,725** | **2,585** | **397** | **11,350** | **987** | **12,067** | **197** | **73,249** | **4,243** | **5.79** |
| **តួលេខឆ្នាំមុន** | | **13,154** | **2,688** | **793** | **380** | **4,174** | **107** | **4,116** | **104** | **11,350** | **1,174** | **12,100** | **411** | **44,894** | **2,589** | **5.77** |
| **ប្រៀបធៀបឆ្នាំមុន** | | **5,559** | **9,907** | **144** | **-102** | **15,347** | **1,618** | **-1,531** | **293** | **-** | **-187** | **-33** | **-214** | **28,355** | **1,654** | **0.03** |

| ល.រ | រាជធានី-ខេត្ត | សណ្តែកដី (ហ.ត) | | សណ្តែកសៀង (ហ.ត) | | ល្ង (ហ.ត) | | អំពៅ (ហ.ត) | | ក្រចៅ (ហ.ត) | | ថ្នាំជក់ (ហ.ត) | | សរុបរួម (ហ.ត) | | ភាគរយ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | ផែនការ | អនុវត្ត | (%) |
| 01 | បន្ទាយមានជ័យ | - | | - | | - | | 110 | | - | | - | | 110 | - | - |
| 02 | បាត់ដំបង | 100 | | | | 100 | | 30 | | | | | | 230 | - | - |
| 03 | កំពង់ចាម | 790 | | - | | 30 | | 360 | | - | | 3,380 | | 4,560 | - | - |
| 04 | កំពង់ឆ្នាំង | 80 | | | | 760 | | 60 | | 10 | | 60 | | 970 | - | - |
| 05 | កំពង់ស្ពឺ | 48 | | - | | - | | - | | - | | - | | 48 | - | - |
| 06 | កំពង់ធំ | 199 | | - | | - | | - | | - | | - | | 199 | - | - |
| 07 | កំពត | 205 | | - | | 30 | | 235 | | - | | - | | 470 | - | - |
| 08 | កណ្តាល | 96 | | 50 | | 150 | | 442 | | - | | - | | 738 | - | - |
| 09 | កោះកុង | - | | - | | - | | 340 | | - | | - | | 340 | - | - |
| 10 | ក្រចេះ | 120 | - | - | - | - | - | 110 | 81 | - | - | - | - | 230 | 81 | 35.22 |
| 11 | មណ្ឌលគិរី | - | | - | | - | | - | | - | | - | | - | - | - |
| 12 | ភ្នំពេញ | - | | - | | | | | | | | | | - | - | - |
| 13 | ព្រះវិហារ | - | | - | | - | | - | | - | | - | | - | - | - |
| 14 | ព្រៃវែង | 130 | | - | | 1,025 | | 175 | | - | | - | | 1,330 | - | - |
| 15 | ពោធិ៍សាត់ | 550 | | 50 | | 200 | | 720 | | - | | - | | 1,520 | - | - |
| 16 | រតនគិរី | | | | | | | | | | | | | - | - | - |
| 17 | សៀមរាប | - | | 10 | | 210 | | 405 | | - | | - | | 625 | - | - |
| 18 | ព្រះសីហនុ | | | | | | | 40 | | | | | | 40 | - | - |
| 19 | ស្ទឹងត្រែង | - | | - | | | | | | | | | | - | - | |
| 20 | ស្វាយរៀង | | | | | | | 523 | | | | | | 523 | - | - |
| 21 | តាកែវ | 122 | 71 | - | | 11 | 17 | 175 | 220 | - | - | - | - | 308 | 308 | 100.00 |
| 22 | ឧត្តរមានជ័យ | - | | - | | - | | - | | - | | - | | - | - | - |
| 23 | កែប | 100 | | - | | - | | 30 | | - | | - | | 130 | - | - |
| 24 | ប៉ៃលិន | 50 | | | 5 | 100 | | 10 | | | | | | 160 | 5 | 3.13 |
| 25 | ត្បូងឃ្មុំ | 230 | | - | | - | | 20 | | - | | 1,340 | | 1,590 | - | - |
| | **សរុប** | **3,624** | **71** | **110** | **5** | **2,616** | **17** | **3,785** | **301** | **10** | **-** | **4,780** | **-** | **14,121** | **394** | **2.79** |
| | **តួលេខឆ្នាំមុន** | **3,624** | **182** | **1,173** | **110** | **2,629** | **-** | **3,688** | **99** | **-** | **-** | **8,930** | **103** | **20,044** | **494** | **2.46** |
| | **ប្រៀបធៀបឆ្នាំមុន** | **-** | **-111** | **-1,063** | **-105** | **-13** | **17** | **97** | **202** | **10** | **-** | **-4,150** | **-103** | **-5,923** | **-100** | **0.33** |

**បានឃើញ និងឯកភាព**

ប្រធាននាយកដ្ឋានផែនការ និងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១៦

ប្រធានការិយាល័យស្ថិតិ